ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៣៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់សហគមន៍ លើផ្ទៃដីទំហំ ៧.៧២៩ ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃ គូលែន-ព្រហ្មទេព ស្ថិតនៅក្នុងឃុំរំដោះស្រែ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ សម្រាប់ផ្តល់ចែកជូនគ្រួសារយោធិន ក្នុងកងពលធំអន្តរាគមន៍លេខ៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៩ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី តំបន់ការពារធម្មជាតិ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា១៖**

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ត្រង់មាត្រា១១ ចំណុច៤ ត្រូវបានកំណត់ទំហំដី ៧ ៧២៩(ប្រាំពីរពាន់ ប្រាំពីររយ ម្ភៃ ប្រាំបួន)ហិកតា ជាតំបន់សហគមន៍ នៃតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងឃុំរំដោះស្រែ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។

តំបន់សហគមន៍ក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព មានផែនទីនិងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

www.pheakdeylaw.com

**មាត្រា២៖**

ផ្ទៃដីតំបន់សហគមន៍ចំនួន ៧ ៧២៩ហិកតានេះ សម្រាប់ផ្តល់ចែកជូនគ្រួសារយោធិន ក្នុងកងពលធំអន្តរាគមន៍លេខ៣។ រាល់សិទ្ធិកាន់កាប់ ប្រើប្រាស់ និងការចាត់ចែងដីក្នុងតំបន់សហគមន៍នេះ ត្រូវអនុវត្តតាមគោលការណ៍របស់រាជរដ្ឋាភិបាល និងនីតិវិធីនៃច្បាប់ជាធរមាន។

**មាត្រា៣៖**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទីតាំងកំណត់តំបន់សហគមន៍ នៃដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងឃុំរំដោះស្រែ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ លើផ្ទៃដីចំនួន ៧.៧២៩ ហិកតា សម្រាប់ផ្តល់ចែកជូនគ្រួសារយោធិន ក្នុងកងពលធំអន្តរាគមន៍លេខ៣

អនុក្រឹត្យ លេខ: ៨៦ អនក្រ.បក
ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣







| និយាមកា លើទីតាំងរួម | | | |
|---|---|---|---|
| ID | N | X | Y |
| 1 | A | 478034 | 1562261 |
| 2 | B | 477248 | 1562022 |
| 3 | C | 477207 | 1561275 |
| 4 | D | 477524 | 1560037 |
| 5 | E | 477215 | 1557763 |
| 6 | F | 479021 | 1555516 |
| 7 | G | 478765 | 1554224 |
| 8 | H | 488023 | 1554224 |
| 9 | I | 488024 | 1556378 |
| 10 | J | 482921 | 1564475 |
| 15 | K | 482096 | 1564592 |
| 16 | L | 480786 | 1563037 |
| 18 | M | 479360 | 1562359 |
| 19 | N | 478043 | 1562004 |

| និយាមកា បរិវេណប្រាសាទ | | | |
|---|---|---|---|
| ID | | X | Y |
| 1 | | 484688 | 1555766 |
| 2 | | 485395 | 1555766 |
| 3 | | 485395 | 1556471 |
| 4 | | 484684 | 1556471 |

**សញ្ញាសំគាល់**

- ● ចំណុចនិយាមកា
- ▨ តំបន់សហគមន៍
- ▩ តំបន់បរិវេណប្រាសាទ
- ▭ ព្រំប្រទល់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព

www.pheakdeylaw.com